01247660

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

ឯកសារលេខ: **D229/3/1/4**

*តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី*
*ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម*
*ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

**សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ២២)**

**ចំពោះមុខ:** **ចៅក្រម ប្រាក់ គីមសាន** **ប្រធាន**
**ចៅក្រម** Olivier BEAUVALLET
**ចៅក្រម និយ ថុល**
**ចៅក្រម** Kang Jin BAIK
**ចៅក្រម ហួត វុទ្ធី**

កាលបរិច្ឆេទ: **ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៦**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 02 / 06 / 2016
ម៉ោង (Time/Heure): 10:15
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Sann Rada

---

**សាធារណៈ:**

**សេចក្តីសម្រេចលើសេចក្តីជូនដំណឹងរបស់ យឹម ទិត្យ អំពីការដកបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើបន្ទាន់សុំឲ្យពិចារណាឡើងវិញលើការដាក់បង្ហាញចម្លើយសាក្សីក្នុងសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២/០២**

---

**<u>សហព្រះរាជអាជ្ញា</u>**
ជា លាង
Nicholas KOUMJIAN

**<u>សហមេធាវីការពារក្តីម្ចាស់បណ្តឹងឧទ្ធរណ៍</u>**
សូ មូស្សេទ្ធី
Susana TOMANOVIĆ

**<u>មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**
ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
Linda BEHNKE
Laure DESFORGES
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Emmanuel JACOMY
Christine MARTINEAU

01247661



ទី ស្រ៊ុនណា　　Barnabe NEKUI

វ៉ែន ពៅ　　Lyma NGUYEN

Beini YE

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C. * C.E.T.C.

01247662



**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”) បានទទួល “សេចក្តីជូនដំណឹងរបស់ យឹម ទិត្យ អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើសំណើរបស់គាត់សុំឱ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិពិចារណាឡើងវិញលើការដាក់បង្ហាញចម្លើយសាក្សីនៃសំណុំរឿង ០០៤ នៅក្នុងសំណុំរឿង ០០២/០២” ដែលបានដាក់នៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៥ ហើយក្រឡាបញ្ជីសហចៅក្រមស៊ើបអង្កេតបានចុះបញ្ជីនៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៥ (“សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍”)[1]។

1. នៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៥ សហមេធាវីការពារក្តី យឹម ទិត្យ បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដែលចេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ HARMON (“សេចក្តីសម្រេចដែលរងការជំទាស់”)[2] ដោយបដិសេធសំណើពីរដែលស្នើសុំពិចារណាឡើងវិញលើការដាក់បង្ហាញចម្លើយសាក្សីពីសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២/០២[3]។

2. នៅថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១៥ មន្ត្រីច្បាប់នៃការិយាល័យសហចៅក្រមស៊ើបអង្កេតបានជូនដំណឹងមកសហមេធាវីថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ BOHLANDER សុំឱ្យចាត់ទុកសេចក្តីសម្រេចដែលរងការជំទាស់ជាមោឃៈ ហើយនឹងចេញសេចក្តីសម្រេចថ្មី ក្នុងពេលឆាប់ៗ[4]។

3. នៅថ្ងៃដដែលនោះ សហមេធាវីបានដាក់សំណើសុំការណែនាំទាក់ទិននឹងការដាក់សេចក្តីសន្និដ្ឋានលើបណ្តឹងឧទ្ធរណ៍ទៅក្រឡាបញ្ជីអង្គបុរេជំនុំជម្រះ[5]។

---

[1] ឯកសារ D229/3/1។

[2] ដីកាសម្រេចលើសំណើបន្ទាន់របស់ យឹម ទិត្យ សុំឱ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិពិចារណាឡើងវិញលើការដាក់បង្ហាញចម្លើយសាក្សីនៃសំណុំរឿង ០០៤ នៅក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៥ ឯកសារ D229/3។

[3] សំណើបន្ទាន់របស់ យឹម ទិត្យ សុំឱ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិពិចារណាឡើងវិញលើការដាក់បង្ហាញចម្លើយសាក្សីនៃសំណុំរឿង ០០៤ នៅក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ D229។ សំណើបន្ទាន់លើកទីពីររបស់ យឹម ទិត្យ សុំឱ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិពិចារណាឡើងវិញលើការដាក់បង្ហាញចម្លើយសាក្សីនៃសំណុំរឿង ០០៤ នៅក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៥ ចុះថ្ងៃទី D229/2។

[4] *សូមមើល* សារអេឡិចត្រូនិកពីមន្ត្រីច្បាប់នៃការិយាល័យសហចៅក្រមស៊ើបអង្កេតផ្ញើជូនសហមេធាវីការពារក្តី យឹម ទិត្យ ចុះថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ D229/3/1/1.1.2។

4. នៅថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១៥ ក្រឡាបញ្ជីអង្គបុរេជំនុំជម្រះបានជូនដំណឹងមកសហមេធាវីថា អង្គបុរេជំនុំជម្រះបានអនុញ្ញាតឱ្យពន្យារពេលកំណត់ ៣០ ថ្ងៃ គិតពីពេលចេញសេចក្ដីសម្រេចជាថ្មី ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ BOHLANDER[6]។

5. នៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ BOHLANDER បានចេញសេចក្ដីសម្រេចដែលរងការជំទាស់ជាថ្មី[7]។

6. សហមេធាវីមិនបានដាក់សេចក្ដីសន្និដ្ឋានណាមួយ លើបណ្ដឹងឧទ្ធរណ៍ទៅតាមពេលកំណត់របស់អង្គបុរេជំនុំជម្រះ ដែលផុតកំណត់នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៦ នោះទេ។

7. នៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៦ អង្គបុរេជំនុំជម្រះបានណែនាំសហមេធាវីឱ្យដាក់សេចក្ដីជូនដំណឹងពីបំណងរបស់ខ្លួន ក្នុងការដាក់សំណើក្នុងរយៈពេល ៥ ថ្ងៃ[8]។

8. នៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៦ សហមេធាវីបានដាក់សេចក្ដីជូនដំណឹងពីការដកបណ្ដឹងឧទ្ធរណ៍[9]។

9. អង្គបុរេជំនុំជម្រះរម្លឹកថា បើផ្អែកលើការអនុវត្តនៅកម្ពុជា និងការអនុវត្តលើឆាកអន្តរជាតិ "ភាគីមានសិទ្ធិដកបណ្ដឹងឧទ្ធរណ៍ រហូតដល់ពេលបិទការដេញដោលរវាងភាគីដោយពុំចាំបាច់សុំការ

---

[5] សំណើរបស់ យឹម ទិត្យ សុំការណែនាំ ពាក់ព័ន្ធនឹងសារអេឡិចត្រូនិកដែលទទួលបានពីមន្ត្រីច្បាប់នៃ ក.ស.ច.ស ដែលបានដាក់នៅថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១៥ និងត្រូវបានជូនដំណឹងនៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ D229/3/1/1។

[6] *សូមមើល* សារអេឡិចត្រូនិកពីមន្ត្រីច្បាប់នៃការិយាល័យសហចៅក្រមស៊ើបអង្កេតផ្ញើជូនសហមេធាវីការពារក្ដី យឹម ទិត្យ ចុះថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ D229/3/1/2.1.2។

[7] សេចក្ដីសម្រេចដែលត្រូវបានចេញជាថ្មី លើសំណើបន្ទាន់របស់ យឹម ទិត្យ សុំឱ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិពិចារណាឡើងវិញលើការដាក់បង្ហាញចម្លើយសាក្សីនៃសំណុំរឿង ០០៤ នៅក្នុងសំណុំរឿង ០០២/០២ ដែលបានដាក់នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៦ និងត្រូវបានជូនដំណឹងនៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ D229/5។

[8] សារអេឡិចត្រូនិកពីអង្គបុរេជំនុំជម្រះដែលផ្ញើជូនភាគី **ការជូនដំណឹង:** សេចក្ដីណែនាំរបស់អង្គបុរេជំនុំជម្រះដល់ភាគីនៅក្នុងសំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ ២២) ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៦។

[9] ការជូនដំណឹងរបស់ យឹម ទិត្យ អំពីការដកបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច D229/5 ដែលបានដាក់នៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៦ និងត្រូវបានជូនដំណឹងនៅថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៦ ឯកសារ D229/3/1/3។

01247664



អនុញ្ញាត”[10]។ នៅក្នុងករណីនេះ សហមេធាវីបានដាក់សេចក្តីជូនដំណឹងស្តីពីការដកបណ្តឹងឧទ្ធរណ៍ មុនពេលចេញសេចក្តីសម្រេច អនុលោមតាមវិធាន ៧៧(៣) នៃវិធានផ្ទៃក្នុង ហេតុនេះ មុនពេលបញ្ចប់ការដេញដោលលើបណ្តឹងឧទ្ធរណ៍។ ហេតុនេះ សហមេធាវីការពារក្តីត្រូវបានអនុញ្ញាតឱ្យបណ្តឹងឧទ្ធរណ៍ដោយពុំចាំបាច់ស្នើសុំឡើយ។

## សេចក្តីសម្រេច

**ផ្អែកលើសំអាងហេតុទាំងនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ៖**

**កត់សម្គាល់**លើការដកបណ្តឹងឧទ្ធរណ៍។

**រាជធានីភ្នំពេញ ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៦**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** **Olivier BEAUVALLET** **នំយ ថុល** **Kang Jin BAIK** **ហួត វុទ្ធី**

[10] សេចក្តីសម្រេចស្តីពីការជូនដំណឹងស្តីពីការដកបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធតាមការសន្មត នូវសំណើសុំចេញដីកាអនុញ្ញាតឱ្យពិនិត្យសំណុំរឿង ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ D121/2/3 កថាខណ្ឌ ២ *យោងដល់* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០៤) សេចក្តីសម្រេចពាក់ព័ន្ធនឹងសេចក្តីជូនដំណឹងអំពីការដកបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៨ ឯកសារ C26/I/31 កថាខណ្ឌ ១១។